សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

**លេខ: ០៩ ក្រ ៤ "វ"**

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**-សំណុំរឿងព្រហ្មទណ្ឌលេខ:១៤១៦**

ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១

**-សំណុំរឿងស៊ើបសួរលេខ:១០៧១**

ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១

**-សំណុំរឿងជំនុំជម្រះលេខ:៣៣២៤**

ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជា***សាធារណៈ*** នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង៨ និង៣០ នាទី ព្រឹក នៅសាលសវនាការទី៥ ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

លោក [redacted] ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៤១៦ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ ដែលជនជាប់ចោទមានឈ្មោះដូចខាងក្រោមនេះ៖

១.ឈ្មោះ [redacted] **កុម្ភៈ** ភេទប្រុស កើតនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម លំនៅបច្ចុប្បន្នស្នាក់នៅផ្ទះមិនចាំលេខ ផ្លូវលេខ២៦២ សង្កាត់បឹងកេង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ៅ "ស" ម្តាយឈ្មោះ [redacted] សារឿន "រ" នៅលើវ ជាទីតិជន ទោសពីមុន គ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:២៥៣៦ "ជ" ជ.ឃ.ជ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។ (ស១)

២.ឈ្មោះ [redacted] **សុបញ្ញា** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តស្វាយរៀង លំនៅបច្ចុប្បន្នស្នាក់បុរីសំណង់វាលស្បូវ ផ្ទះលេខ៥១ ផ្លូវលេខ០៤ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វុទ្ធី "ស" ម្តាយឈ្មោះ [redacted] សុភក្តិ "រ" នៅលើវ ទោសពីមុន គ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:២៥៣៤ "ជ" ជ.ឃ.ជ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។(ស១)

៣.ឈ្មោះ [redacted] **សុក្រទីរៈ ហៅ ម៉ាច់** ភេទប្រុស កើតនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ លំនៅបច្ចុប្បន្នផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុវណ្ណារិទ្ធិ "រ" ម្តាយឈ្មោះ [redacted] សេរីសោភ័ណ្ឌ "រ" នៅលើវ ទោសពីមុន គ្មាន។



Scanned with CamScanner

-ឃាត់ខ្លួននៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:២៥៣៥ "ង" ង.ឃ.ង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។(ម១)

ដោយមានលោក [redacted] ជាសមាជិកគណៈមេធាវីណៃព្រះរាជាណាចក្រកម្ពុជាសមាជិកមេធាវីក្រុមហ៊ុនមេធាវីខ្មែរអស្សេរា លោក [redacted] មានការិយាល័យ **វ៉េនម៉េកឃើ(កម្ពុជា)** លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានតាមមាត្រា ៣៥៣ និងឱ្យផ្តន្ទាទោសមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] KEATYING ភេទស្រី មានអាសយដ្ឋាននៅទីលំនៅបច្ចុប្បន្នផ្ទះលេខ១២៩ មហាវិថីនរោត្តម សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ៖

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ និង៣០នាទី មានជនជាប់ចោទបានជិះម៉ូតូចំនួន០១គ្រឿងបានធ្វើសកម្មភាពឆក់កាបូប ជនរងគ្រោះឈ្មោះ [redacted] KEATYING នៅចំណុចផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ នៅក្នុងកាបូបមានប្រាក់ចំនួន៥០០ (ប្រាំរយ) ដុល្លារអាមេរិក ,កាតATM ចំនួន០១ និងកាតធនាគារសិង្ហបុរីចំនួន០១ ហើយបានគេចខ្លួនបាត់។ បន្ទាប់ជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានធ្វើការស្រាវជ្រាវចាប់ជនជាប់ចោទបានចំនួន០៣នាក់មានឈ្មោះ [redacted] កុម្ភៈ,ឈ្មោះ [redacted] សុក្រវីរៈ និងឈ្មោះ [redacted] សុបញ្ញា សមត្ថកិច្ចកបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញ របាយការណ៍លេខ:០២៨/២០២១ របក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១១០៩ អ.យ.ខ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ:៣០៦៥ អ.យ.ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៤៣៣៦ “ឃ”.ង.ង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] កុម្ភៈ បានឆ្លើយថា នៅថ្ងៃកើតហេតុនោះខ្លួនបានជិះម៉ូតូដើរលេងជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] សុបញ្ញា តាមផ្លូវលេខ៦៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ស្រាប់តែខ្លួនឃើញឈ្មោះ ចេស្តា ឆក់កាបូបរបស់គេ ដោយមានពីរនាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ ខ្លួនភ័យខ្លាចជាប់ពាក់ពន្ធ័ក៏បានបើកម៉ូតូគេចចេញ មិនបានបិទគ្នួចដូចការចោទប្រកាន់ឡើយ។ ចម្លើយរបស់ខ្លួននៅសមត្ថកិច្ចខ្លួនសុំបដិសេធចោលដោយសុំយកចម្លើយនៅពេលសវនាការនេះ ។

-ជនជាប់ចោទឈ្មោះ [redacted] សុបញ្ញា បានឆ្លើយថា នៅថ្ងៃកើតហេតុនេះខ្លួនបានជិះម៉ូតូទៅទិញខោអាវជាមួយឈ្មោះ



Scanned with CamScanner

គុម្ភៈ និងឈ្មោះ [redacted]វីរៈ ដើម្បីទៅទិញខោអាវ ស្រាប់តែមកដល់ចំណុចផ្លូវលេខ៦៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ស្រាប់តែខ្លួនឃើញឈ្មោះ ចេស្តា ឆក់កាបូបរបស់គេ ដោយមានពីរនាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ ខ្លួនភ័យខ្លាចជាប់ពាក់ពន្ធ័ក៏បានបើកម៉ូតូគេចចេញ មិនបានបិទគូថដូចការចោទប្រកាន់ឡើយ។ ចម្លើយរបស់ខ្លួននៅសមត្ថកិច្ចខ្លួនសុំបដិសេធចោលដោយសុំយកចម្លើយនៅពេលសវនាការនេះ ។

-ជនជាប់ចោទឈ្មោះ [redacted] សុក្រវីរៈ បានឆ្លើយថា នៅថ្ងៃកើតហេតុនោះខ្លួនបានជិះម៉ូតូដើរលេងជាមួយឈ្មោះ [redacted] គុម្ភៈ និងឈ្មោះ [redacted]សុបញ្ញា តាមផ្លូវលេខ៦៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ស្រាប់តែខ្លួនឃើញឈ្មោះ ចេស្តា ឆក់កាបូបរបស់គេ ដោយមានពីរនាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ ខ្លួនភ័យខ្លាចជាប់ពាក់ពន្ធ័ក៏បានបើកម៉ូតូគេចចេញ មិនបានបិទគូថដូចការចោទប្រកាន់ឡើយ។ ខ្លួនស្គាល់ឈ្មោះ ចេស្តា តាមរយៈហ្វេសប៊ុក។ ហើយចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅសមត្ថកិច្ចខ្លួនសុំបដិសេធចោលដោយសុំយកចម្លើយនៅពេលសវនាការនេះ។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] KEATYINGកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១២ និង០០នាទី ខ្លួនបានជិះផាស្លាប់មកហូបអាហារនៅម្តុំផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញនៅពេលហូបហើយខ្លួនបានដើរទៅធនាគារ ស្រាប់តែមានមនុស្សចំនួន០២នាក់ជិះម៉ូតូមួយគ្រឿងមកខាងក្រោយបានឆក់កាបូបស្ពាយរបស់ខ្លួន ដោយនៅក្នុងកាបូបនោះមានទូរស័ព្ទចំនួន០២គ្រឿង មានកាបូបតូចនៅខាងក្នុងចំនួន០១ មានប្រាក់ចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិកកាត ABA ចំនួន០១សន្លឹក កាតធនាគារសង្គ្រប៊ូរីចំនួន០១សន្លឹក។

-អំណានរបាយការណ៍សំយោគលេខ: ០២៨/២០២១របក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

***•សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖***

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ ,ជនរងគ្រោះ និងពិនិត្យភស្តុតាងរួចមកឃើញថា ចម្លើយរបស់ជនជាប់ចោទបានឆ្លើយបដិសេធនូវអំពើរបស់ខ្លួន ដោយពុំមានភស្តុតាងណាមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ប៉ុន្តែចម្លើយជនជាប់ចោទបានឆ្លើយនៅសមត្ថកិច្ចបានបញ្ជាក់យ៉ាងច្បាស់ថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ និង ៣០នាទី ឈ្មោះ ចេស្តា និងឈ្មោះ នុត ហៅ ប៊ិយ ជាអ្នកធ្វើសកម្មភាពឆក់កាបូបជនរងគ្រោះ នៅចំណុចផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង ២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ពួកខ្លួនគ្រាន់តែជិះម៉ូតូបិទគូថតែប៉ុណ្ណោះ ចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ជនរងគ្រោះ និងភស្តុតាងមានភាពស៊ីសង្វាក់គ្នាដែលអាចឱ្យតំណាងអយ្យការជឿបាន តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ជនជាប់ចោទទាំងបីរូបនេះ ពិតជាបានប្រព្រឹត្តនូវអំពើដូចការចោទប្រកាន់ប្រាកដមែនដូច្នេះក្នុងនាមជាតំណាងអយ្យការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៣០៦៥ អ.យ.ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។

***•សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖***

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គុម្ភៈ, ឈ្មោះ [redacted] សុក្រវីរៈ និងឈ្មោះ [redacted] សុបញ្ញា បានសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្លួននៅពេលសវនាការនិងពិនិត្យឯកសារក្នុងសំណុំរឿងឃើញថា កូនក្តីខ្លួនពុំបានឆក់កាបូបរបស់ជនរងគ្រោះ កាលពីថ្ងៃ១៧ ខែមីនា ឆ្នាំ២០២១ នៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញនោះទេ ព្រោះថា កូនក្តីខ្លួនគ្រាន់តែឃើញជនជាប់ចោទឈ្មោះ ចេស្តា និងបក្ខពួកបានឆក់កាបូបរបស់ជនរងគ្រោះ ហើយកូនក្តីខ្លួនខ្លាចមានការជាប់ពាក់ពន្ធ័ក៏នាំគ្នាជិះម៉ូតូ



Scanned with CamScanner

គេចចេញតែប៉ុណ្ណោះ។ ម៉្យាងទៀតចម្លើយដែលបានឆ្លើយនៅសមត្ថកិច្ចកូនក្តីខ្លួនបានបញ្ជាក់ហើយថាមានការបង្ខិតបង្ខំនិងពុំបានអានឱ្យកូនក្តីខ្លួនស្តាប់នោះទេ។ ដូចនេះសូមឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

**•សំដីចុងក្រោយរបស់ជនជាប់ចោទ៖**

-ជនជាប់ចោទឈ្មោះ [redacted] ក្មួរ: បាននិយាយសំដីចុងក្រោយសុំឱ្យតុលាការសម្រេចលើកលែងចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] សុក្រវីរៈ បាននិយាយសំដីចុងក្រោយសុំឱ្យតុលាការសម្រេចលើកលែងចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] សុបញ្ញា បាននិយាយសំដីចុងក្រោយសុំឱ្យតុលាការសម្រេចលើកលែងចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់តាមអំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សំអាងហេតុ**

១.កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ និង ៣០នាទី មានជនជាប់ចោទបានជិះម៉ូតូបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] KEATYING នៅចំណុចផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ នៅក្នុងកាបូបមានប្រាក់ចំនួន៥០០ (ប្រាំរយ) ដុល្លារអាមេរិក ,កាតATM ចំនួន០១ និងកាតធនាគារសិង្ហបុរីចំនួន០១ ហើយបានគេចខ្លួនបាត់។ ក្រោយមកសមត្ថកិច្ចបានធ្វើការស្រាវជ្រាវធ្វើការឃាត់ខ្លួនបានជនជាប់ចោទចំនួន០៣នាក់រួមមាន៖ ឈ្មោះ [redacted] ក្មួរ:, ឈ្មោះ [redacted] សុក្រវីរៈ និងឈ្មោះ [redacted] សុបញ្ញា ហើយសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

២.ជនជាប់ចោទឈ្មោះ [redacted] ក្មួរ:, ឈ្មោះ [redacted] សុក្រវីរៈ និងឈ្មោះ [redacted] សុបញ្ញា ត្រូវបានចៅក្រមស៊ើបសួរប្តឹងចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមមាត្រា ៣៥៣ និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៤៣៣៦ "យ" ដ.ដ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ។

៣.ជនជាប់ចោទឈ្មោះ [redacted] ក្មួរ:, ឈ្មោះ [redacted] សុបញ្ញា និងឈ្មោះ [redacted] សុក្រវីរៈ បានឆ្លើយប្រហាក់ប្រហែលគ្នាកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ពួកខ្លួនបានជិះម៉ូតូដើរលេងជាមួយគ្នាតាមផ្លូវលេខ៦៣ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ស្រាប់តែខ្លួនឃើញឈ្មោះ ចេស្តា មានគ្នាពីរនាក់ទៀតបានឆក់កាបូបរបស់គេ ពួកខ្លួនមានការភ័យខ្លាចជាប់ពាក់ពន្ធ័ក៏បានបើកម៉ូតូគេចចេញ មិនបានបិទគូថដូចការចោទប្រកាន់ឡើយ ហើយជនជាប់ចោទទាំងបីរូបនេះបានឆ្លើយបដិសេធនូវចម្លើយរបស់ពួកខ្លួននៅសមត្ថកិច្ចនោះដោយពុំមានហេតុផលអ្វីឡើយ។ ចម្លើយបដិសេធរបស់ជនជាប់ចោទទាំងបីរូបនេះជាចម្លើយដោះសារ ដើម្បីឱ្យពួកគេរួចផុតពីបទចោទប្រកាន់តែប៉ុណ្ណោះ ដោយពុំមានភស្តុតាងណាមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ប៉ុន្តែចម្លើយរបស់ជនជាប់ចោទទាំងបីរូបនេះបានឆ្លើយនៅសមត្ថកិច្ចបានបញ្ជាក់



Scanned with CamScanner

យ៉ាងច្បាស់ថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ និង ៣០នាទី ឈ្មោះ **ចេស្តា** និងឈ្មោះ **ឧត** ហៅ **បិយ** បានជិះម៉ូតូចំនួន០១គ្រឿងធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះនៅចំណុចផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ហើយពួកខ្លួនគ្រាន់តែជិះម៉ូតូបិទគូថតែប៉ុណ្ណោះ ក្រោយពីធ្វើសកម្មភាពហើយឈ្មោះ **ចេស្តា** បានយកប្រាក់មកចែកឱ្យពួកខ្លួននៅមុខវិទ្យាល័យយុគន្ធរ។ ចម្លើយនេះមានភាពស៊ីសង្វាក់នឹងភស្តុតាងដែលអាចឱ្យតុលាការជឿបាន។

៤.តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **KEATYING** បានបញ្ជាក់ថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១២ និង០០នាទី ខ្លួនបានជិះផាស្តាប់មកហូបអាហារនៅម្តុំផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ នៅពេលហូបហើយខ្លួនបានដើរទៅធនាគារ ស្រាប់តែមានជនសង្ស័យចំនួន០២នាក់ជិះម៉ូតូមួយគ្រឿងមកខាងក្រោយបានឆក់កាបូបស្ពាយរបស់ខ្លួន ដោយនៅក្នុងកាបូបនោះមានទូរស័ព្ទចំនួន០២គ្រឿង មានកានបូបតូចនៅខាងក្នុងចំនួន០១មានប្រាក់ចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិកកាត ABA ចំនួន០១សន្លឹក កាតធនាគារសង្ហបូរីចំនួន០១សន្លឹក។ចម្លើយនេះមានភាពច្បាស់និងចម្លើយជនជាប់ចោទអាចឱ្យតុលាការជឿបាន។

៥.ផ្អែកតាមរបាយការណ៍សំយោគរបស់សមត្ថកិច្ច, ចម្លើយសារភាពរបស់ជនជាប់ចោទនៅចំពោះសមត្ថកិច្ច ,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] **កុម្ភៈ**, ឈ្មោះ [redacted] **សុបញ្ញា** និងឈ្មោះ [redacted] **សុក្រវីរៈ** បានជិះម៉ូតូធ្វើសកម្មភាពឆក់កាបូបស្ពាយជនរងគ្រោះឈ្មោះ [redacted] **KEATYING** នៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង ២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។ សកម្មភាពរបស់ជនជាប់ចោទទាំងបីរូបនេះ ត្រូវបានច្បាប់កំណត់ថា ជាអំពើ **លួចមានស្ថានទម្ងន់ទោស** បទល្មើសដែលមានចែងតាមមាត្រា ៣៥៣ និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.សកម្មភាពទាក់ទងនឹងអំពើ **លួចមានស្ថានទម្ងន់ទោស** ត្រូវបានហាមឃាត់ដោយច្បាប់ ដូច្នេះជនជាប់ចោទទាំងបីរូបនេះបានដឹងរួចហើយថា សកម្មភាពដែលពួកខ្លួនបានប្រព្រឹត្តនោះ គឺជាអំពើខុសច្បាប់ ប៉ុន្តែជនជាប់ចោទទាំងបីរូបនេះនៅតែប្រព្រឹត្តដដែល គឺបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទទាំងបីរូបនេះពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តនូវអំពើ **លួចមានស្ថានទម្ងន់ទោស** ដែលច្បាប់បានបញ្ញត្តិថា ជាបទល្មើសនិងត្រូវផ្តន្ទាទោស។

៧.ជនជាប់ចោទឈ្មោះ [redacted] **កុម្ភៈ**, ឈ្មោះ [redacted] **សុបញ្ញា** និងឈ្មោះ [redacted] **សុក្រវីរៈ** មានសតិគ្រប់គ្រាន់មិនមានវិបល្លាសស្មារតី មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ពួកខ្លួនដែលបានប្រព្រឹត្តកន្លងមក។

៨.សកម្មភាពរបស់ជនជាប់ចោទទាំងបីរូបនេះដែលបានប្រព្រឹត្តនូវអំពើ **លួចមានស្ថានទម្ងន់ទោស** ជាអំពើមួយដែលធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គមនិងជាអំពើដែលប្រើអំពើហិង្សាឆក់យកកាបូបស្ពាយរបស់ជនរងគ្រោះមកធ្វើជាកម្មសិទ្ធិរបស់ពួកខ្លួន ហើយក៏ជាបទល្មើសដែលមានចែងតាមមាត្រា**៣៥៣** និងឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការយកមកពិចារណានិងសម្រេច។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **កុម្ភៈ** ភេទប្រុស កើតនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤, ឈ្មោះ [redacted] **សុក្រវីរៈ** ភេទប្រុស កើតនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ និងឈ្មោះ [redacted] **សុបញ្ញា** ភេទប្រុស អាយុ១៨ឆ្នាំ មានអត្តសញ្ញាណខាងលើ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានតាមមាត្រា៣៥៣ និងឱ្យផ្តន្ទាទោសមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១០.តាមការពិនិត្យលើសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ឃើញថា ជនជាប់ចោទឈ្មោះ **ឡេង កុម្ភៈ** កើតនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ ឃើញថា បើគិតដល់ថ្ងៃប្រព្រឹត្តបទល្មើសទើបតែមានអាយុ ***១៧ឆ្នាំ ០១ខែ និង១៣ថ្ងៃ*** តែប៉ុណ្ណោះ គឺជាអនីតិជននៅឡើយ។ ដូច្នេះ តុលាការគប្បីសម្រេចផ្តន្ទាទោសលើជនជាប់ចោទរូបនេះដោយយោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១១.តាមការពិនិត្យលើសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងទំពន់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុព្រះវិរៈ កើតនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ឃើញថា បើគិតដល់ថ្ងៃប្រព្រឹត្តបទល្មើសទើបតែមានអាយុ ***១៧ឆ្នាំ ៧ខែ និង០៩ថ្ងៃ*** តែប៉ុណ្ណោះ គឺជាអនីតិជននៅឡើយ។ ដូច្នេះ តុលាការគប្បីសម្រេចផ្តន្ទាទោសលើជនជាប់ចោទរូបនេះដោយយោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១២.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតម្កល់នីតិកម្មសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់នោះ មានសំអាងហេតុគ្រប់គ្រាន់អាចឱ្យតុលាការយកមកធ្វើការពិចារណាបាន។

១៣.មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់នោះ តុលាការពុំគប្បីយកមកធ្វើការពិចារណាឡើយ ដោយពុំមានភស្តុតាងណាមកបញ្ជាក់ថា កូនក្តីរបស់ខ្លួនពុំមានប្រព្រឹត្តនូវអំពើ **លួចមានស្ថានទម្ងន់ទោស** នោះទេ។

១៤.ជនជាប់ចោទទាំងបីរូបនិយាយសំដីចុងក្រោយ សុំឱ្យសម្រេចឱ្យពួកខ្លួនរួចផុតពីបទចោទប្រកាន់នោះ ពុំមានភស្តុតាង ឬ សាក្សីណាមកបញ្ជាក់ថា ពួកគេពុំបានប្រព្រឹត្តនូវអំពើដូចការចោទប្រកាន់នោះទេ។

១៥.តាមកំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ១៤១៦ វ.វ.ត ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញឃើញថា នៅពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានចាប់យក ម៉ូតូម៉ាកSUZUKI NEX ពណ៌ស ពាក់ស្លាកលេខភ្នំពេញ1IP-0102 ចំនួន០១គ្រឿង (មិនប្រាកដ) ,ទូរស័ព្ទម៉ាក IPHONE X ពណ៌សចំនួន០១គ្រឿង (បែកគួរខាងក្រោយមិនប្រាកដ)ជាមធ្យោបាយប្រព្រឹត្តបទល្មើ និងខ្សែលោហធាតុពណ៌លឿងស្លេក មានបន្តោងព្រះពណ៌ខ្មៅស្រោប លោហធាតុពណ៌លឿងស្លេកចំនួន០១ខ្សែ និងដង្កៀនលោហធាតុពណ៌លឿងស្លេកចំនួន០១ គឺផលដែលបានមកពីការប្រព្រឹត្តបទល្មើស ដូច្នេះតុលាការគប្បីសម្រេចរឹបអូសមាត្រា៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សុបញ្ញា** ភេទប្រុស អាយុ១៨ឆ្នាំ មានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៥(**ប្រាំ**)**ឆ្នាំ**។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **កុម្ភៈ** ភេទប្រុស កើតនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៤ និងឈ្មោះ [redacted] **សុព្រះវិរៈ** ភេទប្រុស កើតនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ មានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ២ (**ពីរ**) **ឆ្នាំ និង ៦** (**ប្រាំមួយ**)**ខែ**។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្លូវលេខ៦៣ចន្លោះផ្លូវលេខ៣៣២ និងផ្លូវលេខ៣៣៤ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១បទល្មើសដែលមានតាមមាត្រា៣៥៣ មាត្រា ១៦០ និងឱ្យផ្តន្ទាទោសមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**៣-រឹបអូសវត្ថុចាប់យករួមមាន៖** ម៉ូតូម៉ាក SUZUKI NEX ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1IP-0102 ចំនួន០១គ្រឿង (មិនប្រាកដ) ,ទូរស័ព្ទម៉ាក IPHONE X ពណ៌ស ចំនួន០១គ្រឿង (បែកគួរខាងក្រោយមិនប្រាកដ) ,ខ្សែលោហធាតុពណ៌លឿងស្លេក មានបន្តោងព្រះពណ៌ខ្មៅស្រោបលោហធាតុពណ៌លឿងស្លេកចំនួន០១ខ្សែ និងដង្កៀនលោហធាតុពណ៌លឿងស្លេកចំនួន០១វង់ ។

សាលក្រមនេះ ជំនុំជម្រះជា ***សវនាការណៈ*** នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងប្រកាសជា ***អ***



Scanned with CamScanner

*សាធារណៈ:* នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជីសវនាការ**

[redacted]

[redacted]